ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សារាចរ

# ស្តីពី

# ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៧ - ២០២៩

# និង

# ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ ២០២៧

# មាតិកា

១.សេចក្តីផ្តើម

២.ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច

៣.ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ

៤.គោលការណ៍ និងបច្ចេកទេសនៃការរៀបចំ ផ.យ.ថ ឆ្នាំ ២០២៧-២០២៩ និងការរៀបចំថវិកាឆ្នាំ ២០២៧

៥.សេចក្តីសន្និដ្ឋាន

# ១.សេចក្តីផ្តើម

អនុលោមតាមមាត្រា ៥១ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី), កសហវ បានដាក់ចេញសារាចរស្តីពីប្រតិទិនសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៧ កាលពីថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០២៦ ដោយបានកំណត់អំពីពេលនៃការរៀបចំក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមឆ្នាំ ២០២៧-២០២៩ និងក្របខ័ណ្ឌថវិការយៈពេលមធ្យមឆ្នាំ ២០២៧-២០២៩ សម្រាប់ជាមូលដ្ឋាននៃការរៀបចំសេចក្តីព្រាងសារាចរស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា (ផ.យ.ថ) និងការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុប្រចាំឆ្នាំ។

ដោយផ្អែកលើក្របខ័ណ្ឌខាងលើ, សារាចរស្តីពីការរៀបចំ ផ.យ.ថ ឆ្នាំ ២០២៧-២០២៩ និងការ-រៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៧ ត្រូវបានដាក់ចេញដើម្បីផ្តល់មគ្គុទ្ទេសក៍បច្ចេកទេសគន្លឹះៗ និងការណែនាំពាក់ព័ន្ធដល់គ្រប់ក្រសួង ស្ថាប័ន, មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលដែលស្ថិតក្រោមក្រសួង ស្ថាប័ននីមួយៗ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់ការរៀបចំថវិកាពាក់ព័ន្ធនឹងមុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ)។

# ២. ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច

| ទស្សនវិស័យសេដ្ឋកិច្ចកម្ពុជា | ឆ្នាំ ២០២៧ |
|---|---|
| កំណើនសេដ្ឋកិច្ច | ៥,០% |
| អតិផរណាជាប្រាក់រៀល (កំណើនមធ្យមប្រចាំឆ្នាំជា%) | ២,៥% |
| អត្រាប្តូរប្រាក់ (រៀល/ដុល្លារ) | ៤ ០៥០ |
| លំហូរទុនវិនិយោគបរទេស (%នៃផ.ស.ស.) | ១១,០% |
| ទុនបម្រុង (ចំនួនខែនៃការនាំចូលទំនិញ និងសេវា) | ៧,៩ |

# ៣.ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ

**អាទិភាពគោលនយោបាយសំខាន់ៗ៖**

- ការការពារអធិបតេយ្យជាតិ និងបូរណភាពទឹកដី ព្រមទាំងធានាស្ថិរភាពនយោបាយ និងម៉ាក្រូសេដ្ឋកិច្ច;
- ការដោះស្រាយលំនឹងជីវភាពប្រជាជន;
- ការជំរុញពិពិធកម្មសេដ្ឋកិច្ច និងអភិវឌ្ឍប្រភពថ្មីនៃកំណើន;
- ការពង្រឹងបរិយាកាសធុរកិច្ច និងការលើកកម្ពស់វិស័យឯកជន;
- ការអភិវឌ្ឍមូលធនមនុស្ស និងសង្គម;
- ការជំរុញបរិវត្តកម្មឌីជីថល និងការអភិវឌ្ឍបៃតង;
- ការពង្រឹងអភិបាលកិច្ច និងស្ថាប័ន។

# ៣.១. ក្របខ័ណ្ឌថវិការយៈពេលមធ្យមឆ្នាំ ២០២៧-២០២៩

## ក្របខ័ណ្ឌតុល្យភាពថវិការយៈពេលមធ្យមឆ្នាំ ២០២៧-២០២៩

| ភាគរយនៃ ផ.ស.ស. | 2026 ច្ប. | 2026 កែ. | 2027ព្យ. | 2028 ព្យ. | 2029 ព្យ. |
|---|---|---|---|---|---|
| **ចំណូលសរុបថវិការដ្ឋ** | **14.89%** | **15.25%** | **15.24%** | **15.16%** | **15.16%** |
| ចំណូលចរន្តថវិការដ្ឋ | 14.37% | 14.73% | 14.76% | 14.70% | 14.68% |
| **ចំណាយសរុបថវិការដ្ឋ** | **18.60%** | **18.60%** | **17.03%** | **16.69%** | **16.43%** |
| ចំណាយចរន្តថវិការដ្ឋ | 12.42% | 12.42% | 12.41% | 12.14% | 11.85% |
| ចំណាយមូលធនថវិការដ្ឋ | 6.18% | 6.18% | 4.62% | 4.54% | 4.58% |
| **អតិរេកចរន្ត** | **1.95%** | **2.31%** | **2.36%** | **2.55%** | **2.83%** |
| **សមតុល្យថវិកា** | **-3.71%** | **-3.36%** | **-1.79%** | **-1.53%** | **-1.26%** |

## ៣.១.១. ក្របខ័ណ្ឌចំណាយរយៈពេលមធ្យមឆ្នាំ ២០២៧-២០២៩

| ប្រភេទចំណាយឆ្នាំ ២០២៧ | %ផសស | បំរែបំរួលធៀបនឹង ច្បា. ២០២៦ |
|---|---|---|
| ចំណាយសរុបថវិកាជាតិ | ១៥,២៤% | ៩,៨% |
| ចំណាយចរន្តថវិកាជាតិ | ១៤,៧៦% | ១០,២% |
| ក្នុងនោះ៖ -ចំណាយគយ និងរដ្ឋាករ | ៥,៨៦% | ១៤,៨% |
| -ចំណាយពន្ធដារ | ៦,៩៩% | ៧,៨% |
| -ចំណាយមិនមែនសារពើពន្ធ | ១,៩១% | ៥,៤% |
| ចំណាយផ្សេងៗ | ០,៤៨% | -១% |

សម្រាប់វិធានការដែលនឹងត្រូវអនុវត្តដោយអគ្គនាយកដ្ឋានពន្ធដារ, អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និង ក្រសួង ស្ថាប័ន និងអង្គភាពប្រមូលចំណូលទាំងអស់, សូមអានបន្ថែមនៅក្នុងសារាចរចាប់ពីទំព័រទី ៩ ដល់ ទី ១២។

## ៣.១.២. ក្របខ័ណ្ឌចំណាយរយៈពេលមធ្យមឆ្នាំ ២០២៧-២០២៩

| ប្រភេទចំណាយឆ្នាំ ២០២៧ | | %ផសស | បំរែបំរួលធៀបនឹងច្បា. ២០២៦ |
|---|---|---|---|
| **ចំណាយសរុបថវិការដ្ឋ** | | ១៧,០៣% | -១,៨% |
| *ក្នុងនោះ៖* | *-ចំណាយចរន្តថវិការដ្ឋ* | *១២,៤១%* | *៧,១%* |
| | *-ចំណាយមូលធនថវិការដ្ឋ* | *៤,៦២%* | *-១៩,៨%* |

- ចំណាយបន្ទុកបុគ្គលិកក្នុងឆ្នាំ ២០២៧ ត្រូវបានគ្រោងឱ្យមានកំណើនក្នុងអត្រា ៨,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៦ ដោយមានការគិតគូរការដំឡើងបៀវត្ស ព្រមទាំងការដំឡើងថ្នាក់ និងឋានន្តរស័ក្តិ។ សម្រាប់ឆ្នាំ ២០២៨-២០២៩ ចំណាយបន្ទុកបុគ្គលិក ត្រូវបានគ្រោងកើនជាមធ្យមក្នុងអត្រា ២,៤%។ សម្រាប់ចំណាយមិនមែនបន្ទុក-បុគ្គលិក ក្នុងឆ្នាំ ២០២៧ ត្រូវបានគ្រោងឱ្យមានកំណើនក្នុងអត្រា ៦,៤% ធៀបនឹងច្បាប់ឆ្នាំ ២០២៦ ស្របតាមគោលការណ៍ពង្រឹងស័ក្តិសិទ្ធភាពនៃការវិភាជថវិកា។ សម្រាប់ឆ្នាំ ២០២៨-២០២៩, ចំណាយមិនមែនបន្ទុកបុគ្គលិកត្រូវបានគ្រោងកើនជាមធ្យមក្នុងអត្រា ៧,២%។

## ៣.១.២. ក្របខ័ណ្ឌចំណាយរយៈពេលមធ្យមឆ្នាំ ២០២៧-២០២៩ (ត)

- ទន្ទឹមនេះ, រាជរដ្ឋាភិបាល បានគិតគូរបង្កើនធនធានបន្ថែមទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយត្រូវបែកចែកចំណូលពីសេវាសាធារណៈក្នុងអត្រា ១៥% សម្រាប់ជាគុណប្រយោជន៍ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈយន្តការ "**មូលនិធិភាគភាព**" ចាប់ពីឆ្នាំ ២០២៧ តទៅ និងបានត្រៀមកញ្ចប់ថវិកាក្នុងឥណទានថវិកាមិនទាន់បែងចែករបស់រាជរដ្ឋាភិបាល សម្រាប់អនុវត្តនូវមុខសញ្ញាថ្មីៗ និងកម្មវិធីអន្តរាគមន៍ ដើម្បីរក្សាលំនឹងជីវភាពប្រជាជន និងលើកកម្ពស់សមធម៌សង្គម ក្នុងករណីចាំបាច់ផងដែរ។

# ៣.១.២. ក្របខ័ណ្ឌចំណាយរយៈពេលមធ្យមឆ្នាំ ២០២៧-២០២៩ ( ត )

% ផ.ស.ស.

| វិស័យ | ២០២៧ | ២០២៨ | ២០២៩ |
|---|---|---|---|
| រដ្ឋបាលទូទៅ | ១,៥៩% | ១,៦១% | ១,៥៧% |
| ការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ | ២,៧១% | ២,៦២% | ២,៥២% |
| សង្គមកិច្ច | ៤,៨២% | ៤,៨៥% | ៤,៧៣% |
| សេដ្ឋកិច្ច | ៣,២៨% | ៣,២១% | ៣,២៤% |

## ៣.១.២. ក្របខ័ណ្ឌចំណាយរយៈពេលមធ្យមឆ្នាំ ២០២៧-២០២៩ (ត)

**ការកំណត់ពិតានចំណាយគោល៖** បន្តអនុវត្តសារាចររបស់ កសហវ ស្តីពីវិធានការវិចារណកម្ម និងការពង្រឹងប្រសិទ្ធភាពចំណាយថវិកាថ្នាក់ជាតិ ដោយបានកាត់ព្យួរផលទានចំណាយប្រេងឥន្ធនៈ និងប្រេងរំអិល ព្រមទាំងចំណាយបេសកកម្មក្នុងប្រទេស និងចំណាយបេសកកម្មក្រៅប្រទេសរបស់ក្រសួង ស្ថាប័នថ្នាក់កណ្តាល។ ចំណាយមិនមែនបន្ទុកបុគ្គលិកតាមវិស័យសម្រាប់ឆ្នាំ ២០២៧ នៅរក្សាកញ្ចប់ស្មើនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៦ ដោយផ្តល់អាទិភាពសម្រាប់ដោះស្រាយតម្រូវការចំណាយចាំបាច់មិនអាចខានបាន ឬមិនអាចពន្យារពេលបាន និងចំណាយតាមគោលការណ៍កំណត់ច្បាស់លាស់។ ការកំណត់ពិតានចំណាយគោលសម្រាប់ក្រសួង ស្ថាប័ន ផ្នែកចំណាយមិនមែនបន្ទុកបុគ្គលិក ជាទូទៅត្រូវបានផ្តល់ទាបជាងច្បាប់ថវិកាឆ្នាំ ២០២៦។ ជារួមគឺ ក្រសួង ស្ថាប័ន ត្រូវបានដកចេញនូវសកម្មភាពដែលត្រូវបញ្ចប់ក្នុងឆ្នាំ ២០២៦ ឬកាត់បន្ថយមុខចំណាយមិនប្រចាំ, ការកាត់សន្សំបង្កើនស័ក្តិសិទ្ធភាពចំណាយ (Spending Efficiency), ព្រមទាំងធ្វើវិចារណកម្មចំណាយមួយចំនួន ជាពិសេសចំណាយដែលអាចសន្សំសំចៃបាន ទាំងលើទិដ្ឋភាពប្រសិទ្ធភាពបច្ចេកទេស និងទាំងលើទិដ្ឋភាពតម្លៃនៃលុយ។

## ៣.១.២. ក្របខ័ណ្ឌចំណាយរយៈពេលមធ្យមឆ្នាំ ២០២៧-២០២៩ (ត)

តាមរយៈក្របខ័ណ្ឌថវិការយៈពេលមធ្យម៖

- **ពិតានចំណាយគោលផ្នែកចរន្ត** ត្រូវបានកំណត់សម្រាប់ គ្រប់ក្រសួង ស្ថាប័ន
- **ពិតានចំណាយគោលផ្នែកចំណាយមូលធនសម្រាប់គម្រោងវិនិយោគផ្ទាល់ដោយហិរញ្ញប្បទានថវិកាថ្នាក់ជាតិ** ត្រូវបានកំណត់សម្រាប់ ក្រសួង ស្ថាប័ន ចំនួន ១១
- **ពិតានចំណាយគោលផ្នែកចំណាយមូលធនដោយហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍ** ត្រូវបានកំណត់សម្រាប់ ក្រសួង ស្ថាប័ន ចំនួន ១០

សម្រាប់ជាមូលដ្ឋានក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៧-២០២៩ និងសម្រាប់ការរៀបចំគម្រោងថវិកាឆ្នាំ ២០២៧។

សម្រាប់វិធានការសំខាន់ៗ ដែលក្រសួង ស្ថាប័នត្រូវអនុវត្ត សូមអានសារាចរចាប់ពីទំព័រទី ១៦ ដល់ទី ១៧។

## ៤. គោលការណ៍ និងបច្ចេកទេសនៃការរៀបចំ ផ.យ.ថ. ឆ្នាំ ២០២៧-២០២៩ និងការរៀបចំថវិកាឆ្នាំ ២០២៧

## ៤.១. គោលការណ៍ និងបច្ចេកទេសនៃការរៀបចំ ផ.យ.ថ. ឆ្នាំ ២០២៧-២០២៩

- ផ.យ.ថ. គឺជាឧបករណ៍ដ៏សំខាន់សម្រាប់៖ (១)-ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយរបស់ក្រសួង ស្ថាប័ន និងគោលនយោបាយរួមរបស់រាជរដ្ឋាភិបាល, (២)-បង្កើនវិចារណកម្មអាទិភាពចំណាយរបស់ក្រសួង ស្ថាប័ន, (៣)-ធានានិរន្តរភាពនៃការអនុវត្តកម្មវិធីរបស់ក្រសួង ស្ថាប័ន, (៤)-ជាមូលដ្ឋានសម្រាប់ការពន្យល់ និងការបង្ហាញសេចក្តីសំអាងអំពីតម្រូវការថវិកាសម្រាប់ការងារអាទិភាព និង (៥)-ជាមូលដ្ឋានសម្រាប់ការរៀបចំ និងវិភាជថវិកាប្រចាំឆ្នាំឱ្យចំគោលដៅអាទិភាព។

- ផ.យ.ថ. ជាឯកសាររួមមួយ ដែលត្រូវគ្របដណ្តប់ទាំងថវិការដ្ឋបាលកណ្តាល, ថវិកាមន្ទីរជំនាញរាជធានី ខេត្ត និងថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ ព្រមទាំងថវិការបស់រដ្ឋបាលថ្នាក់ក្រោម-ជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ដោយត្រូវធ្វើសមាហរណកម្មថវិកាចរន្ត និងថវិកាមូលធន ព្រមទាំងរវាងថវិកាជាតិ និងថវិកាហិរញ្ញប្បទានសហ-ប្រតិបត្តិការ។

## ៤.១. គោលការណ៍ និងបច្ចេកទេសនៃការរៀបចំ ផ.យ.ថ. ឆ្នាំ ២០២៧-២០២៩ (ត)

- ក្រសួង ស្ថាប័នត្រូវជំរុញ និងលើកទឹកចិត្តដល់ **ក្រុមការងារថវិកា** របស់ខ្លួនដែលមានសមាសភាពមកពីអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ/អគ្គលេខាធិការដ្ឋាន ដែលហៅថា "**អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ**", ទទួលបន្ទុកសម្របសម្រួល និងការចូលរួមប្រកបដោយបុរេសកម្មពីអង្គភាពថវិកា ដែលជាអគ្គនាយកដ្ឋាន និងអង្គភាពជំនាញ ព្រមទាំងអង្គភាពគ្រប់គ្រងគម្រោង ដើម្បីធានាបាននូវ ផ.យ.ថ. ដែលមានគុណភាព និងភាពគ្រប់ជ្រុងជ្រោយ។
- ផ្អែកលើកញ្ចប់ថវិកាក្នុងកម្រិតពិតានចំណាយគោល, ក្រសួង ស្ថាប័នត្រូវរៀបចំផែនការថវិការយៈពេលមធ្យម (៣ ឆ្នាំ) ដោយត្រូវគោរពតាមពិតានចំណាយគោលដែលបានផ្តល់ជូន។ ក្រសួង ស្ថាប័នត្រូវបានអនុញ្ញាតឱ្យគ្រោងនូវតម្រូវការធនធានថវិកាសម្រាប់អនុវត្តគោលនយោបាយថ្មីៗ ដែលទើបមានការសម្រេចពីរាជរដ្ឋាភិបាលនៅក្នុងឆ្នាំអនុវត្តថវិកានេះ។
- ក្រុមការងារថវិកាត្រូវខិតខំធានាឱ្យប្រាកដថា ទាំងធនធាន និងសកម្មភាពអាទិភាពទាំងអស់ត្រូវបានដាក់បញ្ចូល ឬឆ្លុះបញ្ចាំងក្នុង ផ.យ.ថ.។
- គ្រប់ក្រសួង ស្ថាប័ន ត្រូវរៀបចំ ផ.យ.ថ. តាមទម្រង់នៃឧបសម្ព័ន្ធ ១។

## ៤.១. គោលការណ៍ និងបច្ចេកទេសនៃការរៀបចំ ផ.យ.ថ. ឆ្នាំ ២០២៧-២០២៩ (ត)

- ស្របតាមស្មារតីនៃអនុក្រឹត្យលេខ ២៤២ ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០២១ ស្ដីពី "ការបង្កើនចំនួនអង្គភាពថវិកា និងការប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិជូនអង្គភាពថវិកា", ក្រសួង ស្ថាប័ន ត្រូវកំណត់ **អង្គភាពថវិកា** និងអ្នកគ្រប់គ្រង ទៅតាមកម្រិតនៃរចនាសម្ព័ន្ធកម្មវិធី (កម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព) ឱ្យបានច្បាស់លាស់ ដើម្បីធានាឱ្យមានបន្ទាត់គណនេយ្យភាព ដែលមានការទទួលខុសត្រូវច្បាស់លាស់ក្នុងការគ្រប់គ្រង និងអនុវត្តថវិកា។ កសហវ នឹងផ្ដល់ការបណ្ដុះ-បណ្ដាលសមត្ថភាពផ្នែកថវិកា និងនីតិវិធីហិរញ្ញវត្ថុ ក៏ដូចជាផ្ដល់ប្រឹក្សាផ្នែកបច្ចេកទេសពាក់ព័ន្ធតាមការចាំបាច់ ជូនដល់ទាំងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ និងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញ ដើម្បីមានសមត្ថភាពពេញលេញក្នុងការអនុវត្តថវិកាព័ត៌មានសមិទ្ធកម្ម។

## ៤.១.១. ការគ្រោងចំណូលថវិកាសម្រាប់ឆ្នាំ ២០២៧-២០២៩

ការគ្រោងចំណូលត្រូវផ្ដោតការយកចិត្តទុកដាក់លើចំណុចសំខាន់ដូចខាងក្រោម៖

- វាយតម្លៃការអនុវត្តការប្រមូលចំណូលក្នុងឆ្នាំកន្លងទៅ និងការប៉ាន់ស្មានការអនុវត្តប្រមូលចំណូលក្នុងឆ្នាំកំពុងអនុវត្ត ដើម្បីគ្រោងចំណូលឆ្នាំ ២០២៧ និងព្យាករចំណូលឆ្នាំ ២០២៨-២០២៩
- ដាក់ចេញវិធានការដាក់ស្ដែងបន្ថែមទៀតតាមក្រសួង ស្ថាប័ននីមួយៗ ដើម្បីបង្កើនការប្រមូលចំណូលដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួន។

*ការគ្រោងចំណូលមិនអស់សក្ដានុពល គឺជាកម្មវត្ថុនៃការរឹតត្បិតចំណាយ នៅក្នុងកិច្ចប្រជុំការពារគម្រោងថវិកាប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័ន ដែលមានភារកិច្ចប្រមូលចំណូល។*

## ៤.១.២. ការគ្រោងចំណាយថវិកាសម្រាប់ឆ្នាំ ២០២៧-២០២៩

ការគ្រោងចំណាយ ត្រូវផ្តោតការយកចិត្តទុកដាក់លើចំណុចសំខាន់ៗ ដូចខាងក្រោម៖

- ពិតានចំណាយគោល ដែលបានផ្តល់ជាកញ្ចប់ថវិកាសម្រាប់រយៈពេល ៣ ឆ្នាំ (២០២៧-២០២៩)
- ការវាយតម្លៃការអនុវត្តចំណាយក្នុងឆ្នាំកន្លងមក និងការប៉ាន់ស្មានសមត្ថភាពអនុវត្តចំណាយក្នុងឆ្នាំ ២០២៦ ដែលបាននិងកំពុងអនុវត្ត,
- ការកំណត់តម្រូវការថវិកាតាមឆ្នាំនីមួយៗ ត្រូវគណនាតម្រូវការជាក់ស្តែងនៃកម្មវិធីនីមួយៗ និងត្រូវស្របតាមបញ្ជីស្តង់ដាថ្លៃទំនិញ និងសេវា ដែលកំណត់និងដាក់ឱ្យអនុវត្តដោយ កសហវ ដោយត្រូវគិតគូរឈរលើទិដ្ឋភាព ៣ គឺ៖
  - **ផែនការសកម្មភាពការងារ ឬគម្រោងដែលមានស្រាប់ដែលត្រូវបន្តអនុវត្ត**
  - **សកម្មភាពការងារដែលបញ្ចប់ត្រឹមមួយឆ្នាំ (One-Off) និង**
  - **សកម្មភាពការងារថ្មី តាមការសម្រេចរបស់រាជរដ្ឋាភិបាល។**

# ៤.១.២. ការគ្រោងចំណាយថវិកាសម្រាប់ឆ្នាំ ២០២៧-២០២៩ (ត)

√ ចំណាយបន្ទុកបុគ្គលិក (ជំពូក ៦៤)

| ឆ្នាំ ២០២៧ | ឆ្នាំ ២០២៨ | ឆ្នាំ ២០២៩ |
|---|---|---|
| -**មូលដ្ឋានក្របខ័ណ្ឌ**ឆ្នាំ ២០២៦ និងជ្រើសរើសក្របខ័ណ្ឌថ្មី យ៉ាងច្រើនស្មើនឹងចំនួនមន្ត្រីចូលនិវត្តន៍ឆ្នាំ ២០២៦ ប៉ុន្តែការរើសដាក់ស្តែង គឺជាកម្មវត្ថុនៃការឯកភាពពីក្រសួងមុខងារសាធារណៈ<br>-**បៀវត្សមូលដ្ឋាន** ត្រូវរក្សាស្មើនឹងកម្រិតឆ្នាំ ២០២៦ (តម្លៃសន្ទស្សន៍ ១ ឯកតា = ២ ៦៣០ រៀល)។ ទន្ទឹមនេះ, ក្រសួង ស្ថាប័នអាចគ្រោងថវិកាសម្រាប់ការដំឡើងឋានន្តរស័ក្តិ និងថ្នាក់ប្រចាំឆ្នាំ ស្របតាមបទប្បញ្ញត្តិជាធរមាន។ | -គ្រោងក្នុងកម្រិតក្របខ័ណ្ឌ និងកម្រិតបៀវត្សដែលបានគ្រោងសម្រាប់ឆ្នាំ ២០២៧ ហើយចំនួនក្របខ័ណ្ឌថ្មីយ៉ាងច្រើនត្រូវស្មើនឹងចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍ និងផ្អែកលើការវិភាគមុខងារដែលទទួលបានការឯកភាពពីក្រ.មុខងារសាធារណៈ។ | -គ្រោងក្នុងកម្រិតក្របខ័ណ្ឌ និងកម្រិតបៀវត្សដែលបានគ្រោងសម្រាប់ឆ្នាំ ២០២៨ ហើយចំនួនក្របខ័ណ្ឌថ្មីយ៉ាងច្រើនត្រូវស្មើនឹងចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍ និងផ្អែកលើការវិភាគមុខងារដែលទទួលបានការឯកភាពពីក្រ.មុខងារសាធារណៈ។ |

# ៤.១.២. ការគ្រោងចំណាយថវិកាសម្រាប់ឆ្នាំ ២០២៧-២០២៩ (ត)

√ ចំណាយបន្ទុកបុគ្គលិក (ជំពូក ៦៤)

| ឆ្នាំ ២០២៧ | ឆ្នាំ ២០២៨ | ឆ្នាំ ២០២៩ |
|---|---|---|
| **-ប្រាក់បំណាច់មុខងារ៖** ត្រូវដំឡើងប្រាក់បំណាច់មុខងារប្រចាំខែចំនួន **៥ ម៉ឺនរៀល** ជូនដល់មន្ត្រីរាជការស៊ីវិល, មន្ត្រីនគរបាលជាតិ និងយោធិន ដែលមានប្រាក់បំណាច់មុខងារ**ក្រោម ៨០០ ០០០ រៀល** និងដំឡើងប្រាក់បំណាច់មុខងារប្រចាំខែចំនួន **៣ ម៉ឺនរៀល** ជូនដល់មន្ត្រីរាជការស៊ីវិល, មន្ត្រីនគរបាលជាតិ និងយោធិន ដែលមានប្រាក់បំណាច់មុខងារ**ចាប់ពី ៨០០ ០០០ រៀល** ឡើងទៅ ដោយគិតចាប់ពីខែ មករា ដល់ខែ ធ្នូ។ | -គ្រោងតាមគោល-ការណ៍ឆ្នាំ ២០២៧ | -គ្រោងតាមគោល-ការណ៍ឆ្នាំ២០២៨ |
| -គ្រោងប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ **ចំនួន ៥ ម៉ឺនរៀល/នាក់** និងក្នុងឱកាសបុណ្យភ្ជុំបិណ្ឌ **ចំនួន ៥ ម៉ឺនរៀល/នាក់** ជូនដល់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ព្រមទាំងនិវត្តន៍ជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលជាអតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន | -គ្រោងតាមគោល-ការណ៍ឆ្នាំ ២០២៧ | -គ្រោងតាមគោល-ការណ៍ឆ្នាំ ២០២៨ |
| **-មន្ត្រីជាប់កិច្ចសន្យា៖** ត្រូវគ្រោងមិនឱ្យលើសពីចំនួន ដែលក្រសួងមុខងារសាធារណៈផ្តល់ជូនក្នុងឆ្នាំ ២០២៦ និងដោយមានការឯកភាពពី កសហវ ចំពោះមន្ត្រីជាប់កិច្ចសន្យាត្រូវគ្រោងដំឡើងពី **៧៩ ម៉ឺនរៀល** ទៅដល់ **៨១ ម៉ឺនរៀល** ដោយគិតចាប់ពីខែ មករា ដល់ខែ ធ្នូ។ | -គ្រោងតាមគោល-ការណ៍ឆ្នាំ ២០២៧ | -គ្រោងតាមគោល-ការណ៍ឆ្នាំ ២០២៨ |

## ៤.១.២. ការគ្រោងចំណាយថវិកាសម្រាប់ឆ្នាំ ២០២៧-២០២៩ (ត)

√ ចំណាយក្រៅបន្ទុកបុគ្គលិក (ជំពូក ៦០, ៦១, ៦២ និង ៦៥)

| បរិយាយ | ឆ្នាំ ២០២៧ | ឆ្នាំ ២០២៨ | ឆ្នាំ ២០២៩ |
|---|---|---|---|
| **ក្រសួង ស្ថាប័ន** | គ្រោងតាមទំហំពិតានចំណាយគោល ឆ្នាំ ២០២៧-២០២៩ ប៉ុន្តែកញ្ចប់ថវិកាតាម **ពិតានចំណាយគោលនឹងមិនទទួលបានជាស្វ័យប្រវត្តិនោះទេ** គឺនៅជាកម្មវត្ថុនៃការពិនិត្យ និងពិភាក្សា | គ្រោងតាមទំហំពិតានចំណាយ គោលឆ្នាំ ២០២៧-២០២៩ | គ្រោងតាមទំហំពិតានចំណាយ គោលឆ្នាំ ២០២៧-២០២៩ |
| **មន្ទីរនៃក្រសួង ស្ថាប័ននិងរដ្ឋបាលថ្នាក់ក្រោមជាតិ** (មុខងារមានភ្ជាប់ ល.ខ ក្នុងវិស័យសុខាភិបាល | គ្រោងតាមពិតានចំណាយគោលរួម ឆ្នាំ ២០២៧-២០២៩ ប៉ុន្តែកញ្ចប់ថវិកា ដែលគ្រោងផ្តល់នេះ **មិនទទួលបានជាស្វ័យប្រវត្តិនោះទេ**<br>* សម្រាប់មុខងារមានភ្ជាប់ល.ខ ក្នុងវិស័យអប់រំ, ការគ្រោងកញ្ចប់ថវិកាត្រូវអនុវត្តតាមបទប្បញ្ញត្តិជាធរមាន។ | គ្រោងតាមតាមពិតានចំណាយ គោលរួមឆ្នាំ ២០២៧-២០២៩ និងគោលការណ៍ឆ្នាំ ២០២៧ | គ្រោងតាមតាមពិតានចំណាយ គោលរួមឆ្នាំ ២០២៧-២០២៩ និងគោលការណ៍ឆ្នាំ ២០២៧ |

# ៤.១.២. ការគ្រោងចំណាយថវិកាសម្រាប់ឆ្នាំ ២០២៧-២០២៩ (ត)

√ ចំណាយក្រៅបន្ទុកបុគ្គលិក (ជំពូក ៦០, ៦១, ៦២ និង ៦៥)

| បរិយាយ | ឆ្នាំ ២០២៦ | ឆ្នាំ ២០២៧ | ឆ្នាំ ២០២៨ |
| --- | --- | --- | --- |
| **គ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ** | គ្រោងតាមទំហំពិតានចំណាយគោលឆ្នាំ ២០២៧-២០២៩ ប៉ុន្តែកញ្ចប់ឧបត្ថម្ភធនដែលគ្រោងផ្តល់នេះ **មិនទទួលបានជាស្វ័យប្រវត្តិនោះទេ** គឺនៅជាកម្មវត្ថុនៃការពិនិត្យ និងពិភាក្សា | គ្រោងតាមទំហំពិតានចំណាយគោលឆ្នាំ ២០២៧-២០២៩ | គ្រោងតាមទំហំពិតានចំណាយគោលឆ្នាំ ២០២៧-២០២៩ |

- រាល់គម្រោងចំណាយទាំងអស់ត្រូវភ្ជាប់ជាមួយនូវឯកសារពាក់ព័ន្ធរួមមាន៖ ការសិក្សា, វិភាគ, វាយតម្លៃ និងការផ្តល់អំណះអំណាងត្រឹមត្រូវ និងច្បាស់លាស់ ទើបអាចដាក់ជាកម្មវត្ថុនៃការពិចារណា និងពិភាក្សាការពារ នៅពេលរៀបចំកញ្ចប់ថវិកាប្រចាំឆ្នាំបាន។

## ៤.១.២. ការគ្រោងចំណាយថវិកាសម្រាប់ឆ្នាំ ២០២៧-២០២៩ (ត)

√ ចំណាយក្រៅបន្ទុកបុគ្គលិក (ជំពូក ៦០, ៦១, ៦២ និង ៦៥)

| បរិយាយ | ឆ្នាំ ២០២៧ | ឆ្នាំ ២០២៨ | ឆ្នាំ ២០២៩ |
|---|---|---|---|
| ចំណាយមូលធន/ វិនិយោគផ្ទាល់ដោយហិរញ្ញប្បទានថវិកា-ជាតិ | គ្រោងតាមពិតានចំណាយគោលឆ្នាំ ២០២៧-២០២៩ សម្រាប់ក្រសួង ស្ថាប័នទាំង ១១ (សាធារណការ, អភិវឌ្ឍន៍ជនបទ, ធនធានទឹក, កសិកម្ម, មហាផ្ទៃ, អប់រំ, ការងារ, សុខាភិបាល, កសហវ, ប្រៃសណីយ៍ និងឧស្សាហកម្ម)។ | គ្រោងតាមពិតានចំណាយគោលឆ្នាំ ២០២៧-២០២៩ សម្រាប់ក្រសួង ស្ថាប័នទាំង ១១ | គ្រោងតាមពិតានចំណាយគោលឆ្នាំ ២០២៧-២០២៩ សម្រាប់ក្រសួង ស្ថាប័នទាំង ១១ |
| ចំណាយមូលធន/ វិនិយោគផ្ទាល់ដោយហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍ | គ្រោងតាមពិតានចំណាយគោលឆ្នាំ ២០២៧-២០២៩ សម្រាប់ក្រសួង ស្ថាប័នទាំង ១០ (សាធារណការ, អភិវឌ្ឍន៍ជនបទ, ធនធានទឹក,កសិកម្ម, អប់រំ, ការងារ, សុខាភិបាល, កសហវ, ប្រៃសណីយ៍ និងឧស្សាហកម្ម)។ | គ្រោងតាមពិតានចំណាយគោលឆ្នាំ ២០២៧-២០២៩ សម្រាប់ក្រសួង ស្ថាប័នទាំង ១០ | គ្រោងតាមពិតានចំណាយគោលឆ្នាំ ២០២៧-២០២៩ សម្រាប់ក្រសួង ស្ថាប័នទាំង ១០ |

# ៤.២. គោលការណ៍ និងបច្ចេកទេសនៃការរៀបចំថវិកាឆ្នាំ ២០២៧
## ៤.២.១. ការគ្រោងចំណូលថវិកាឆ្នាំ ២០២៧

| មូលដ្ឋានគ្រោងសម្រាប់ចំណូលសារពើពន្ធ |
|---|
| លទ្ធផលដែលសម្រេចនៅក្នុងឆ្នាំកំពុងប្រព្រឹត្តទៅ ( ឆ្នាំ ២០២៦ ) |
| ចំណូលបន្ថែមដែលសង្ឃឹមថានឹងប្រមូលបាន |
| ការប៉ាន់ស្មានលើការអភិវឌ្ឍសេដ្ឋកិច្ច និងអាជីវកម្មនៅពេលខាងមុខ |
| ការប្រែប្រួលអត្រា និងមូលដ្ឋានប្រមូលពន្ធ |

## ៤.២.១. ការគ្រោងចំណូលថវិកាឆ្នាំ ២០២៧ (ត)

| មូលដ្ឋានគ្រោងសម្រាប់ចំណូលមិនមែនសារពើពន្ធ |
|---|
| **ចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ៖** ត្រូវបន្តសិក្សាលទ្ធភាពកែសម្រួលកម្រៃសេវា និងអត្រាសួយសារពាក់ព័ន្ធនឹងការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ និងការកែសម្រួលកិច្ចសន្យាសម្បទានគ្រប់ប្រភេទ និងកិច្ចសន្យាជួលសេវាកម្មគ្រប់ប្រភេទ, ត្រូវពិនិត្យ និងជំរុញក្រុមហ៊ុនដែលទទួលបានសិទ្ធិពីរដ្ឋសម្រាប់គម្រោងសម្បទានដីសេដ្ឋកិច្ច និងក្រុមហ៊ុនដែលធ្វើការសិក្សាស្រាវជ្រាវ និងធ្វើអាជីវកម្មធនធានរ៉ែ ឧស្ម័ន និងប្រេងកាតជាដើម ឱ្យបន្តដំណើរការអនុវត្តតាមកិច្ចសន្យា ឬចាត់វិធានការសមស្របចំពោះករណីមិនមានអនុលោមភាព ព្រមទាំងត្រូវបន្តកែលម្អការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងការប្រមូលបំណុលដែលត្រូវទារជាដើម។ល។ |
| **ផ្នែកចំណូលមិនមែនសារពើពន្ធ៖** វិធានការលម្អិតមានកំណត់នៅទំព័រទី ១២ នៃសារាចរនេះ។ ទន្ទឹមនេះ, ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវគិតគូរដាក់ចេញនូវវិធានការដាក់ស្តែងបន្ថែម ដើម្បីពង្រឹងការកៀរគរ៖<br>➢ ចំណូលពីប្រភពដែលនៅមានសក្តានុពល មានដូចជា ចំណូលពីសម្បទានរ៉ែ, ចំណូលពីវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍, ផលទុនសកម្មភាពទេសចរណ៍, អាគារស្ថានទូត និងផលទុនរបស់អាកាសចរស៊ីវិលដែលត្រូវបានរំពឹងទុកថានឹងមានកំណើន,<br>➢ ចំណូលដែលអាចមានកំណើន តាមរយៈការពង្រឹងអភិបាលកិច្ចស្ថាប័ន ដោយត្រូវរៀបចំដាក់ចេញនូវផែនការសកម្មភាពជាក់លាក់នៅតាមក្រសួង ស្ថាប័ន។ |

## ៤.២.២. ការគ្រោងចំណាយថវិកាឆ្នាំ ២០២៧

- **ថវិកាព័ត៌មានសមិទ្ធកម្ម** ឬហៅខ្លីថា **"ថវិកាសមិទ្ធកម្ម"** ត្រូវបានដាក់ឱ្យអនុវត្តចាប់ពីឆ្នាំ ២០២៦ ស្របតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។
- ក្រសួង ស្ថាប័ន មន្ទីរជំនាញ និងគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ ព្រមទាំងរដ្ឋបាលថ្នាក់-ក្រោមជាតិ (សម្រាប់មុខងារបានប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ)៖
  - ✓ ត្រូវយកចិត្តទុកដាក់លើកកម្ពស់ស័ក្តិសិទ្ធភាពនៃការវិភាជ ដោយផ្តោតលើ លទ្ធផល ឬធាតុចេញ (Output) ដែលនឹងត្រូវសម្រេចបាន។ ក្រសួង ស្ថាប័ន ត្រូវពង្រឹងបន្ថែមនូវប្រសិទ្ធភាពនៃការគ្រោងថវិកាតាមរចនាសម្ព័ន្ធកម្មវិធី ដែលជាមូលដ្ឋានសម្រាប់ការពិភាក្សាការពារគម្រោងថវិកាក៏ដូចជាសម្រាប់ការធ្វើវិមជ្ឈការសិទ្ធិអំណាចនៃការអនុវត្តចំណាយផងដែរ។
  - ✓ ត្រូវយកចិត្តទុកដាក់ផងដែរលើការកែលម្អរចនាសម្ព័ន្ធកម្មវិធី និងរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលឱ្យកាន់តែស៊ីសង្វាក់គ្នា និងមានលក្ខណៈសមាហរណកម្មក្នុងកម្រិតវិស័យ។
  - ✓ ត្រូវយកចិត្តទុកដាក់កំណត់គោលបំណង និងកត្តាកំណត់ជោគជ័យនៃកម្មវិធី និងអនុកម្មវិធី ឱ្យបានល្អ ដើម្បីធានាបាននូវការផ្សារភ្ជាប់ថវិកាទៅនឹងគោលបំណងគោលនយោបាយ ជាពិសេសត្រូវកំណត់សូចនាករគន្លឹះ និងគោលដៅសូចនាករឱ្យបានត្រឹមត្រូវ និងច្បាស់លាស់។

## ៤.២.២. ការគ្រោងចំណាយថវិកាឆ្នាំ ២០២៧ (ត)

- ***ការរៀបចំផែនការសមិទ្ធកម្ម (Annual Performance Plan - APP)៖***

- ក្រសួង ស្ថាប័ននីមួយៗ ត្រូវរៀបចំផែនការសមិទ្ធកម្ម (សូចនាករគន្លឹះ និងគោលដៅសូចនាករ) ប្រចាំឆ្នាំ ដូចមានភ្ជាប់ក្នុង **តារាង ក** ដើម្បី កសហវ ពិនិត្យអនុលោមភាព និងចងក្រង ដាក់ជាឯកសារឧបសម្ព័ន្ធនៃសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៧ ព្រមទាំងសម្រាប់ជាកម្មវត្ថុនៃការតាមដានវឌ្ឍនភាពនៃការអនុវត្តថវិកាសមិទ្ធកម្ម (*លម្អិតបន្ថែមជូននៅស្លាយបន្ទាប់*)។

- ក្នុងន័យនេះ, ក្រសួង ស្ថាប័នត្រូវផ្ញើ **ផែនការសមិទ្ធកម្ម** ដោយភ្ជាប់មកជាមួយនឹងគម្រោងថវិកាឆ្នាំ ២០២៧ របស់ខ្លួនមក កសហវ (អគ្គនាយកដ្ឋានថវិកា) តាមកាលបរិច្ឆេទកំណត់ក្នុងសារាចរនេះ។

- ***កិច្ចព្រមព្រៀងសមិទ្ធកម្មត្រូវបានកំណត់ជា ៣ កម្រិត៖ (១) រវាងកសហវ និងក្រសួង ស្ថាប័នសាមី, (២) រវាងរដ្ឋមន្ត្រីក្រសួង ស្ថាប័ន និងអ្នកគ្រប់គ្រងកម្មវិធី និង (៣) រវាងអ្នកគ្រប់គ្រងកម្មវិធី និងប្រធានអង្គភាពថវិកា។***

- ក្រសួង ស្ថាប័ន ត្រូវរៀបចំកិច្ចព្រមព្រៀងសមិទ្ធកម្ម តាមកញ្ចប់ថវិកាដែលទទួលបានឯកភាព និងវិភាជជូន តាមស្មារតីនៃការពិភាក្សាការពារគម្រោងថវិកាកម្រិតថ្នាក់ដឹកនាំក្រសួង។

## ៤.២.២. ការគ្រោងចំណាយថវិកាឆ្នាំ ២០២៧ (ត)

- ក្នុងគោលបំណងកែលម្អទម្រង់ **ផែនការសមិទ្ធកម្មប្រចាំឆ្នាំ** ឱ្យកាន់តែគ្រប់ជ្រុងជ្រោយ និងឆ្លុះបញ្ចាំងពីគោលដៅរយៈពេលមធ្យម, គ្រប់ក្រសួង ស្ថាប័នត្រូវបន្ថែម និងកែសម្រួលព័ត៌មានចាំបាច់មួយចំនួន ក្នុងផែនការសមិទ្ធកម្មឆ្នាំ ២០២៧ ក្នុងនោះ៖

***ក-ព័ត៌មានដែលត្រូវបញ្ចូលបន្ថែមក្នុងផែនការសមិទ្ធកម្ម រួមមាន៖*** គោលបំណងគោលនយោបាយរបស់ក្រសួង ស្ថាប័ន, ឯកតាដែលជារង្វាស់នៃសូចនាករ, គោលដៅសូចនាករសម្រាប់ឆ្នាំ N+2 (២០២៨) និងឆ្នាំ N+3 (២០២៩)។

***ខ-ព័ត៌មានដែលត្រូវកែសម្រួល៖*** គោលបំណងកម្មវិធីដែលវែង និងមានភាពស្មុគស្មាញ ត្រូវបានលើកទឹកចិត្តឱ្យបំបែកជាគោលបំណងតូចៗ ប៉ុន្តែមិនត្រូវមានលើសពី ៣ ក្នុងមួយកម្មវិធីទេ។

***គ-កម្មវិធី "ការគ្រប់គ្រងស្ថាប័ន និងសេវាគាំទ្រទូទៅ"៖*** ក្រសួង ស្ថាប័ន ដែលមានកម្មវិធីលើសពីមួយ និងមានកម្មវិធី "ការគ្រប់គ្រងស្ថាប័ន និងសេវាគាំទ្រទូទៅ" នៅក្នុងកម្មវិធីចុងក្រោយ ដែលជាកម្មវិធីគាំទ្រ ត្រូវមានសូចនាករលទ្ធផលចុងក្រោយ ចំនួនពីរជាអប្បបរមា ដូចខាងក្រោម៖

| សូចនាករ | ឯកតា | គោលដៅ |
|---|---|---|
| ១. ភាគរយនៃការអនុវត្តថវិកាធៀបនឹងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ | % | >=៩៥% |
| ២. ប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រង និងត្រួតពិនិត្យផ្ទៃក្នុង | % | >= ៦០% (ត្រូវបានពង្រឹង) |

## ៤.២.២. ការគ្រោងចំណាយថវិកាឆ្នាំ ២០២៧ (ត)

ក្រសួង ស្ថាប័ន អាចគណនា និងវាស់វែងសូចនាករទី២ "ប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រង និងត្រួតពិនិត្យផ្ទៃក្នុង" តាមរយៈការកំណត់**សូចនាកររង** (សំដៅដល់សូចនាករនៅកម្រិតអនុកម្មវិធី) ដែលពាក់ព័ន្ធនឹងការងារស្នូលចំនួន ៥ ដូចខាងក្រោម៖

- **ការគ្រប់គ្រងធនធានមនុស្ស៖** មានជាអាទិ៍ ការងារពាក់ព័ន្ធនឹងការបណ្ដុះបណ្ដាលពង្រឹងសមត្ថភាព, ភាពទាន់ពេលនៃការបើកប្រាក់បៀវត្ស
- **ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ៖** រួមមានការងារពាក់ព័ន្ធនឹងបច្ចុប្បន្នភាពទិន្នន័យទ្រព្យសម្បត្តិរដ្ឋជាដើម
- **ការតាមដាននិងវាយតម្លៃ៖** មានជាអាទិ៍ ការងារពាក់ព័ន្ធនឹងការចុះតាមដាន ត្រួតពិនិត្យសមិទ្ធកម្ម, ការរៀបចំផែនការ និងរបាយការណ៍សមិទ្ធកម្ម
- **សវនកម្មផ្ទៃក្នុង៖** រួមមានការចុះធ្វើសវនកម្មផ្ទៃក្នុង និងការអនុលោមតាមអនុសាសន៍សវនកម្មជាដើម
- **អក្ខរកម្មឌីជីថល៖** សំដៅដល់ការងារពាក់ព័ន្ធនឹងការប្រើប្រាស់ឌីជីថលជារួម ប្រកបដោយការយល់ដឹង និងការទទួលខុសត្រូវ។

ក្រសួង ស្ថាប័នមានភាពបត់បែនក្នុងការរៀបចំសូចនាកររងពាក់ព័ន្ធនឹងការងារស្នូលយ៉ាងតិច ២ ក្នុងចំណោមការងារស្នូលទាំង ៥ ខាងលើ ទៅតាមស្ថានភាពការងារជាក់ស្ដែង ប៉ុន្តែត្រូវធានាឱ្យបាននូវលក្ខណៈវិនិច្ឆ័យរបស់សូចនាករ រួមមាន៖ **ការផ្ដោតលើលទ្ធផល, អាចវាស់វែងបាន, ងាយយល់, មានសុពលភាព និងអាចទុកចិត្តបាន**។ បន្ទាប់ពី ក្រសួង ស្ថាប័ន មានសូចនាកររងពាក់-ព័ន្ធនឹងការងារស្នូលចាប់ពី ២ ឡើងទៅ, ក្រសួង ស្ថាប័ន អាចវាស់វែងសូចនាករ "ប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រង និងត្រួតពិនិត្យផ្ទៃក្នុង" ដោយយកភាគរយ នៃលទ្ធផលសម្រេចបានរបស់សូចនាកររងនីមួយៗ បូកបញ្ចូលគ្នា និងគណនារកមធ្យមភាគ ដើម្បីអាចធ្វើការសន្និដ្ឋានបាន ដូចខាងក្រោម៖

- មធ្យមភាគ **ចាប់ពី ៦០% ឡើងទៅ** មានន័យថា "ប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រង និងត្រួតពិនិត្យផ្ទៃក្នុង **ត្រូវបានពង្រឹង**"។
- មធ្យមភាគ **ក្រោម ៦០%** មានន័យថា "ប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រង និងត្រួតពិនិត្យ ផ្ទៃក្នុង**មិនត្រូវបានពង្រឹង**"។

## ៤.២.២. ការគ្រោងចំណាយថវិកាឆ្នាំ ២០២៧ (ត)

- **គ្រប់ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ** (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ត្រូវរៀបចំគម្រោងចំណាយចាំបាច់ ព្រមទាំងត្រូវឆ្លុះបញ្ចាំងដោយលម្អិត ទៅតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា ព្រមទាំងត្រូវវិភាគឱ្យបានច្បាស់លាស់អំពីតម្រូវការចំណាយតាមចង្កោមសកម្មភាព អនុកម្មវិធី និងកម្មវិធី និងត្រូវភ្ជាប់មកជាមួយនូវឯកសារសម្រាប់គាំទ្រ និងពន្យល់អំពីភាពចាំបាច់នៃតម្រូវការចំណាយលើសកម្មភាពការងារនីមួយៗ ឱ្យបានគ្រប់ជ្រុងជ្រោយ ហើយឯកសារទាំងនេះក៏ជាកម្មវត្ថុសម្រាប់ការត្រួតពិនិត្យ ពិភាក្សា និងការពារគម្រោងថវិកាផងដែរ។
- ការគណនាតម្រូវការចំណាយត្រូវផ្អែកលើកត្តាដែលទាក់ទងនឹងមុខសញ្ញាចំណាយ ដូចជាចំណាយបន្ទុកបុគ្គលិក និងចំណាយមិនមែនបន្ទុកបុគ្គលិក ដែលត្រូវប៉ាន់ស្មានតម្លៃធាតុចូលដែលត្រូវការជាក់ស្តែង ដោយធៀបនឹងតម្រូវការប្រើប្រាស់ក្នុងឆ្នាំ ២០២៥ និងការប៉ាន់ស្មាននៃការអនុវត្តក្នុងឆ្នាំ ២០២៦ និងដោយផ្អែកលើថ្លៃឯកតា **ស្របតាមបញ្ជីស្តង់ដារថ្លៃទំនិញ និងសេវាដែលបានកំណត់ដោយ កសហវ** ឬថ្លៃទីផ្សារ (ក្នុងករណីមិនមានកំណត់ក្នុងបញ្ជីស្តង់ដារថ្លៃទំនិញនិងសេវា) ក៏ដូចជា តាមគោលរបបកំណត់ជាដើម។

## ៤.២.២. ការគ្រោងចំណាយថវិកាឆ្នាំ ២០២៧ (ត)

- កសហវ បានរៀបចំ និងដាក់ឱ្យអនុវត្ត **ស្តង់ដាថ្លៃទំនិញ និងសេវាសម្រាប់កិច្ចលទ្ធកម្មសាធារណៈ** ដើម្បីធានាបាននូវតម្លាភាព, គណនេយ្យភាព និងប្រសិទ្ធភាពនៃចំណាយសាធារណៈ ដោយពង្រីកវិសាលភាពនៃការអនុវត្តសម្រាប់ការរៀបចំថវិកាឆ្នាំ ២០២៧ ទៅដល់ ២០ ក្រសួង ស្ថាប័ន រួមមាន៖ កសហវ, យុត្តិធម៌, រ៉ែនិងថាមពល, ធម្មការនិងសាសនា, ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, មហាផ្ទៃ, ពាណិជ្ជកម្ម, ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, កិច្ចការនារី, អង្គភាពប្រឆាំងអំពើពុករលួយ, *មុខងារសាធារណៈ, អាជ្ញាធរសេវនកម្មជាតិ, ក្រុមប្រឹក្សាធម្មនុញ្ញ, រដ្ឋសភា, ព្រឹទ្ធសភា, ធនធានទឹក និងឧតុនិយម, អភិវឌ្ឍន៍ជនបទ, សុខាភិបាល, ព័ត៌មាន និងកិច្ចការព្រំដែន*។

## ៤.២.២. ការគ្រោងចំណាយថវិកាឆ្នាំ ២០២៧ (ត)

គោលការណ៍ និងបណ្ដាវិធានការសម្រាប់ការគ្រោងចំណាយ៖

- **ក. ចំណាយបន្ទុកបុគ្គលិក (ជំពូក ៦៤)**

- **ចំនួនក្របខ័ណ្ឌថ្មី** ត្រូវគ្រោងយ៉ាងច្រើន **ស្មើនឹងចំនួនមន្ត្រីចូលនិវត្តន៍ក្នុងឆ្នាំ ២០២៦** ប៉ុន្តែការជ្រើសរើសជាក់ស្តែងគឺជាកម្មវត្ថុនៃការឯកភាពពីក្រសួងមុខងារសាធារណៈ។ ទន្ទឹមនេះ, មន្ត្រីដែលព្យួរការងារ និងមន្ត្រីចូលបម្រើការងារវិញ ក៏ជាកម្មវត្ថុនៃការគ្រប់គ្រងឱ្យបានត្រឹមត្រូវ និងហ្មត់ចត់ផងដែរ។
- **បៀវត្សមូលដ្ឋាន៖** ត្រូវរក្សាស្មើនឹងកម្រិតឆ្នាំ ២០២៦ (តម្លៃសន្ទស្សន៍ក្នុង ១ ឯកតា = ២ ៦៣០ រៀល)។ ទន្ទឹមនេះ, ក្រសួង ស្ថាប័នអាចគ្រោងថវិកាសម្រាប់ការដំឡើងឋានន្តរស័ក្តិ និងថ្នាក់ប្រចាំឆ្នាំ ស្របតាមបទប្បញ្ញត្តិជាធរមាន។

| ប្រាក់បំណាច់មុខងារ | ក្រោម ៨០០ ០០០ រៀល | ចាប់ពី ៨០០ ០០០ រៀល ឡើង |
|---|---|---|
| ប្រាក់បំណាច់មុខងារដែលត្រូវដំឡើង | ៥០ ០០០ រៀល | ៣០ ០០០ រៀល |

## ៤.២.២. ការគ្រោងចំណាយថវិកាឆ្នាំ ២០២៧ (ត)

គោលការណ៍ និងបណ្តាវិធានការសម្រាប់ការគ្រោងចំណាយ៖

- **ក. ចំណាយបន្ទុកបុគ្គលិក (ជំពូក ៦៤)**

- **គ្រោងប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីចូលឆ្នាំថ្មីប្រពៃណីជាតិ**ចំនួន **៥ ម៉ឺនរៀល ក្នុងម្នាក់** និង**ក្នុងឱកាសបុណ្យភ្ជុំបិណ្ឌ**ចំនួន **៥ ម៉ឺនរៀល ក្នុងម្នាក់**។
- **គ្រោងចំនួនមន្ត្រីកិច្ចសន្យាមិនឱ្យលើសចំនួន** ដែលក្រសួងមុខងារសាធារណៈផ្តល់ជូនក្នុងឆ្នាំ ២០២៦ និងមានការឯកភាពពី កសហវ។ ចំពោះមន្ត្រីជាប់កិច្ចសន្យា ត្រូវគ្រោងដំឡើងពី ៧៩ ម៉ឺនរៀល ទៅដល់ ៨១ ម៉ឺនរៀល ដោយគិតចាប់ពីខែ មករា ដល់ខែ ធ្នូ។
- **គ្រប់ក្រសួង ស្ថាប័ន (ទាំងថ្នាក់កណ្តាល និងមន្ទីរជំនាញរាជធានី ខេត្ត) ត្រូវគ្រោងចំណាយបន្ទុកបុគ្គលិក ទៅតាមកម្មវិធី អនុកម្មវិធី និងច.ស. នីមួយៗ** ស្របតាមគោលការណ៍ណែនាំស្តីពីការរៀបចំថវិកាសមិទ្ធកម្ម។ ក្នុងន័យនេះ, គ្រប់ក្រសួង ស្ថាប័ន ត្រូវពិនិត្យឱ្យហ្មត់ចត់លើការអនុវត្តជាក់ស្តែងនាឆ្នាំកន្លងទៅ និងឆ្នាំកំពុងអនុវត្ត ដើម្បីបង្កើនសុក្រឹតភាពដល់ការគ្រោងចំណាយបន្ទុកបុគ្គលិកទៅតាមកម្មវិធី អនុកម្មវិធី និង ច.ស. នីមួយៗ។

## ៤.២.២. ការគ្រោងចំណាយថវិកាឆ្នាំ ២០២៧ (ត)

- ខ. <u>ចំណាយក្រៅបន្ទុកបុគ្គលិក</u> (ជំពូក ៦០, ៦១, ៦២, ៦៥)

គ្រប់ក្រសួង ស្ថាប័ន ត្រូវបន្តអនុវត្តសារាចររបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញស្តីពីវិធានការសន្សំសំចៃលើការប្រើប្រាស់ប្រេងឥន្ធនៈ និងអគ្គិសនី និងសារាចររបស់ កសហវ ដែលបានដាក់ចេញស្តីពីវិធាន-ការវិចារណកម្ម និងការពង្រឹងប្រសិទ្ធភាពចំណាយថវិកាថ្នាក់ជាតិ ដោយត្រូវកាត់សន្សំចំណាយលើប្រេងឥន្ធនៈ និងប្រេងរំអិល, លើចំណាយបេសកកម្មក្នុងប្រទេស និងចំណាយបេសកកម្មក្រៅប្រទេស របស់ក្រសួង ស្ថាប័ន ថ្នាក់កណ្តាល។ ដូចនេះ គ្រប់ក្រសួង ស្ថាប័ន ត្រូវបន្តពិនិត្យកាត់បន្ថយជាអតិបរមា នូវការធ្វើដំណើរឆ្ងាយក្នុងការរៀបចំសិក្ខាសាលា និងកិច្ចប្រជុំនានាជាលក្ខណៈរូបវន្ត ដោយលើកទឹកចិត្តឱ្យធ្វើតាមប្រព័ន្ធអនឡាញជំនួសវិញ លើកលែងតែករណីចាំបាច់ប៉ុណ្ណោះ។ ចំពោះការចូលរួមកិច្ចប្រជុំនានានៅក្រៅប្រទេស, ស្នើក្រសួង ស្ថាប័ន ផ្អាកការចូលរួមក្នុងកិច្ចប្រជុំដែលពុំសូវចាំបាច់, ហើយក្នុងករណីចាំបាច់ខានមិនបាន ដែលតម្រូវឱ្យមានតំណាងរបស់កម្ពុជាចូលរួមប្រជុំ, ក្រសួង ស្ថាប័ន គប្បីស្នើសុំទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដើម្បីចាត់តំណាងស្ថានទូតប្រចាំ នៅប្រទេសម្ចាស់ផ្ទះ ចូលរួមកិច្ចប្រជុំនោះ ជំនួសវិញ។ ក្នុងន័យនេះ, ចំពោះការចូលរួមកិច្ចប្រជុំជាលក្ខណៈរូបវន្តនៅក្រៅប្រទេស ស្នើក្រសួង ស្ថាប័នជ្រើសរើសតែកិច្ចប្រជុំដែលមានលក្ខណៈយុទ្ធសាស្ត្រ និងចាំបាច់ខ្លាំងបំផុតប៉ុណ្ណោះ។

# ៤.២.២. ការគ្រោងចំណាយថវិកាឆ្នាំ ២០២៧ (ត)

❖ ខ. ចំណាយក្រៅបន្ទុកបុគ្គលិក (ជំពូក ៦០, ៦១, ៦២, ៦៥)

## ១. កំណត់ចំណាយជាប្រចាំ

មានតម្រូវការចំណាយជារៀងរាល់ឆ្នាំ ដែលរួមមានការចំណាយសម្ភារផ្គត់ផ្គង់ និងថៃទាំជាប្រចាំ និងសម្ភារផ្គត់ផ្គង់រដ្ឋបាលជាប្រចាំ។ ចំណាយប្រភេទនេះ **ត្រូវកំណត់ឱ្យបានត្រឹមត្រូវ និងបង្កើតមូលដ្ឋានគណនាឱ្យបានច្បាស់លាស់**ទៅតាមតម្រូវការជាក់ស្តែង ព្រមទាំង**វិភាជទៅតាមអង្គភាពថវិកា នាយកដ្ឋាន ឬអង្គភាពជំនាញដោយផ្ទាល់**។

## ២ កំណត់ចំណាយមិនជាប្រចាំ

ជាចំណាយដែលមិនកើតឡើងជារៀងរាល់ឆ្នាំ រួមមានការចំណាយបំពាក់ឧបករណ៍សម្ភារដឹកជញ្ជូន សម្ភារបរិក្ខារបច្ចេកទេស គ្រឿងសង្ហារិម និងឧបករណ៍សម្ភារប្រើប្រាស់ផ្សេងៗ។ សម្រាប់ចំណាយប្រភេទនេះ **គឺត្រូវគ្រោងដោយមានមូលដ្ឋានគណនាច្បាស់លាស់** អំពីតម្រូវការ រយៈពេលអនុវត្ត និងប្រសិទ្ធភាពនៃការប្រើប្រាស់ សម្រាប់ទាំងរយៈពេលខ្លី និងរយៈពេលមធ្យម។

# ៤.២.២. ការគ្រោងចំណាយថវិកាឆ្នាំ ២០២៧ (ត)

| អង្គភាព | គោលការណ៍នៃការគ្រោងថវិកា |
|---|---|
| ក្រសួង ស្ថាប័ន | ត្រូវគ្រោងថវិកាទៅតាមទំហំពិតានចំណាយគោលឆ្នាំ ២០២៧ ប៉ុន្តែ**កញ្ចប់ថវិកាតាមពិតានចំណាយគោលនេះ នឹងមិនទទួលបានជាស្វ័យប្រវត្តិនោះទេ**។ រាល់ការគ្រោងចំណាយទាំងអស់ ត្រូវភ្ជាប់ជាមួយនូវឯកសារពាក់ព័ន្ធ រួមមានការសិក្សាវិភាគ វាយតម្លៃ និងអំណះអំណាងត្រឹមត្រូវ ជាក់លាក់ និងច្បាស់លាស់ ទើបអាចជាក់ជាកម្មវត្ថុនៃការពិចារណា និងពិភាក្សាការពារនៅពេលរៀបចំកញ្ចប់ថវិកាប្រចាំឆ្នាំបាន។ មានន័យថា ពិតានចំណាយគោល នៅតែជាកម្មវត្ថុសម្រាប់ការពិភាក្សានៅពេលការពារគម្រោងថវិកា ដើម្បីបង្កើនស័ក្តិសិទ្ធភាពនៃការវិភាជថវិកា ក៏ដូចជាដើម្បីសន្សំសំចៃថវិកាសម្រាប់បំពេញតម្រូវការចំណាយចាំបាច់ថ្មី។ |
| មន្ទីរនៃក្រសួង ស្ថាប័ន និង រដ្ឋបាល រាជធានី ខេត្ត | ផ្អែកលើទំហំពិតានចំណាយគោលរួមដែលផ្តល់ជូនដល់មន្ទីរជំនាញរាជធានី ខេត្ត, សម្រាប់ឆ្នាំ ២០២៧ មន្ទីរជំនាញរាជធានី ខេត្ត និងរដ្ឋបាលរាជធានី ខេត្ត (សម្រាប់មុខងារមានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល) ត្រូវគ្រោងថវិកាយ៉ាងច្រើនបំផុតស្មើនឹងកម្រិតអតិបរមានៃទំហំពិតានចំណាយគោលរួម។ **ក៏ប៉ុន្តែ កញ្ចប់ថវិកាតាមពិតានចំណាយគោលនេះ នឹងមិនទទួលបានជាស្វ័យប្រវត្តិទេ** គឺតម្រូវឱ្យមន្ទីរជំនាញ និងរដ្ឋបាលរាជធានី ខេត្ត ត្រូវផ្តល់ឯកសារពាក់ព័ន្ធដែលមានការសិក្សា វិភាគ វាយតម្លៃ និងអំណះអំណាងត្រឹមត្រូវ ជាក់លាក់ និងច្បាស់លាស់ ព្រោះការគ្រោងចំណាយត្រូវកាត់ចេញមុខចំណាយលើសកម្មភាពការងារដែលត្រូវបានបញ្ចប់ ពិសេសចំណាយមិនប្រចាំ ដើម្បីសន្សំសំចៃសម្រាប់បំពេញតម្រូវការសកម្មភាពថ្មីដែលចាំបាច់តាមគោលនយោបាយ របស់រាជរដ្ឋាភិបាល។ |

# ៤.២.២. ការគ្រោងចំណាយថវិកាឆ្នាំ ២០២៧ (ត)

| អង្គភាព | គោលការណ៍នៃការគ្រោងថវិកា |
|---|---|
| មុខងារមានភ្ជាប់ល.ខ ក្នុងវិស័យអប់រំ | គ្រោងកញ្ចប់ថវិកាត្រូវអនុវត្តតាមបទប្បញ្ញត្តិជាធរមាន សម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ និងសម្រាប់គាំទ្រផ្នែករដ្ឋបាលដល់ការអនុវត្តមុខងារអប់រំ យុវជន និងកីឡានៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ |
| គ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ | ត្រូវបានផ្តល់ពិតានចំណាយគោលសម្រាប់ឧបត្ថម្ភធន **ប៉ុន្តែកញ្ចប់ឧបត្ថម្ភធន ដែលគ្រោងផ្តល់នេះមិនទទួលបានជាស្វ័យប្រវត្តិទេ** គឺតម្រូវឱ្យគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិនីមួយៗ ត្រូវផ្តល់ការពន្យល់ និងអំណះអំណាងត្រឹមត្រូវ ជាក់លាក់ និងច្បាស់លាស់នូវស្ថានភាពចំណូលផ្ទាល់របស់គ្រឹះស្ថាន និងម្យ៉ាងទៀត ក៏ត្រូវកាត់ចេញនូវទំហំចំណាយសម្រាប់សកម្មភាពដែលត្រូវបានបញ្ចប់ ជាពិសេសចំណាយមិនប្រចាំ ដើម្បីសន្សំសំចៃក៏ដូចជាសម្រាប់បំពេញតម្រូវការសកម្មភាពថ្មីដែលចាំបាច់។ |

## ៤.២.២. ការគ្រោងចំណាយថវិកាឆ្នាំ ២០២៧ (ត)

ចំណាយក្រៅបន្ទុកបុគ្គលិកត្រូវគ្រោងដោយឈរលើមូលដ្ឋានដូចខាងក្រោម៖

- **បន្តអនុវត្តសកម្មភាពការងារកំពុងដំណើរការ៖** ការគ្រោងត្រូវផ្អែកលើបរិមាណធាតុចូលដែលធ្លាប់ប្រើក្នុងឆ្នាំ ២០២៥ កន្លងមក និងការប៉ាន់ស្មានអនុវត្តក្នុងឆ្នាំ ២០២៦ និងដោយផ្អែកលើតម្លៃឯកតាជាក់ស្តែងលើទីផ្សារ ហើយជៀសវាងការបង្កើនបរិមាណធាតុចូលលើសពីតម្រូវការ។ ត្រូវមានការ-សន្សំសំចៃលើមុខសញ្ញាដូចជា៖ ទិញឧបករណ៍, សម្ភារបរិក្ខារទំនើប, គ្រឿងសង្ហារិមប្រណិត, ការ-បោះពុម្ពប្រណិត, សម្ភារការិយាល័យ, ប្រេងឥន្ធនៈ, ការទទួលភ្ញៀវអធិកអធម, បេសកកម្មក្នុង និងក្រៅប្រទេស, សេវាទូរគមនាគមន៍, អគ្គិសនី ទឹក, កិច្ចប្រជុំ, សិក្ខាសាលាថ្នាក់ជាតិ និងអន្តរជាតិ, ការតាំងពិព័រណ៍។ សម្រាប់កិច្ចប្រជុំពាក់ព័ន្ធនឹងអាស៊ាន ត្រូវបានអនុញ្ញាតសម្រាប់តែកិច្ចប្រជុំដែលត្រូវវេន។ ករណីដែលមិនចំវេន ត្រូវសុំគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាល។

- ត្រូវកាត់ចេញនូវមុខសញ្ញាដែលមានតម្រូវការតែក្នុងឆ្នាំ ២០២៦ ហើយលែងត្រូវការក្នុងឆ្នាំ ២០២៧ ឬជាសកម្មភាពការងារដែលបានបញ្ចប់ (One-off) ចំណាយប្រភេទនេះត្រូវកាត់ចេញពីគម្រោងថវិកាឆ្នាំ ២០២៧។ លើសពីនេះ, ត្រូវកាត់ចេញនូវទំហំចំណាយនៃសកម្មភាពការងារមួយចំនួនដែលត្រូវបានវាយតម្លៃថាលែងមានសារៈសំខាន់។

## ៤.២.២. ការគ្រោងចំណាយថវិកាឆ្នាំ ២០២៧ (ត)

- ថវិកាដែលកាត់ចេញពីមុខចំណាយ ឬសកម្មភាពការងារដែលត្រូវបានបញ្ចប់ មិនមែនជាកម្មវត្ថុនៃការវិភាជឡើងវិញជាស្វ័យប្រវត្តិនោះទេ លុះត្រាតែមានសកម្មភាពការងារចាំបាច់ថ្មី ឬគោលនយោបាយថ្មីដែលមានការសម្រេចច្បាស់លាស់ពីរាជរដ្ឋាភិបាលជាយថាហេតុ ដែលត្រូវអនុវត្ត និងដែលត្រូវបានលើកឡើងនៅក្នុង ផ.យ.ថ. ឆ្នាំ ២០២៧-២០២៩ និងមានយុត្តិការណ៍អំពីភាពចាំបាច់ និងបន្ទាន់ ព្រមទាំងមានការពន្យល់ និងផ្តល់អំណះអំណាងច្បាស់លាស់ និងត្រឹមត្រូវ ដោយភ្ជាប់មកជាមួយនូវគម្រោងចំណាយលម្អិតច្បាស់លាស់ ទើបចាត់ទុកជាកម្មវត្ថុនៃការត្រួតពិនិត្យ និងពិភាក្សាអំពីលទ្ធភាពថវិកា។

- ចំពោះ **តម្រូវការចំណាយបន្ថែមលើសពីកញ្ចប់ពិតានចំណាយគោល ដែលផ្តល់ជូនក្រសួង ស្ថាប័ននីមួយៗ** ចាំបាច់ត្រូវឆ្លងការពិភាក្សាថវិកាកម្រិតបច្ចេកទេស និងពិនិត្យសម្រេចក្នុងការពិភាក្សាថវិកាកម្រិតថ្នាក់ដឹកនាំ ឬក្នុងករណីចាំបាច់ រដ្ឋមន្ត្រី កសហវ នឹងស្នើសុំការសម្រេច ឬស្នើសុំការសម្រេចឡើងវិញពីរាជរដ្ឋាភិបាលបន្ទាប់ពីមានឯកសារទស្សនាទាន យុត្តិការណ៍ស្តីពីគោលនយោបាយ និងកម្មវិធី ឬមុខសញ្ញាចំណាយ និងតម្លៃច្បាស់លាស់។

- ត្រូវបង្កើនវិមជ្ឈការនៃការផ្ទេរចំណាយរដ្ឋបាលជាប្រចាំ និងសោហ៊ុយបេសកកម្មក្នុង និងក្រៅប្រទេសជាដើមទៅតាមអង្គភាពថវិកា ឱ្យបានកម្រិតអតិបរមា។

## ៤.២.២. ការគ្រោងចំណាយថវិកាឆ្នាំ ២០២៧ (ត)

- ដើម្បីអនុវត្តផែនការសកម្មភាពនៃយុទ្ធសាស្ត្រនានារបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវរៀបចំជាផែនការសកម្មភាពការងារទៅតាមកម្មវិធី និងលើកសំណើសុំថវិកាក្នុងក្របខ័ណ្ឌនៃកញ្ចប់ថវិការួមប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័ននីមួយៗ។ ទន្ទឹមនេះ, ក្រសួង ស្ថាប័ននីមួយៗ ត្រូវគិតគូរពិចារណា ដាក់បញ្ចូលទៅក្នុងគម្រោងថវិកានូវបណ្តាអាទិភាពបន្សាំ និងកាត់បន្ថយការប្រែប្រួលអាកាសធាតុ ដូចមានចែងនៅក្នុងផែនការស្តីពីការចូលរួមចំណែករបស់ជាតិ ដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (២០២០) និងយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលវែងប្រកបដោយអព្យាក្រឹតកាបូន។ កសហវ នឹងពិនិត្យ និងវិភាជថវិកាជូនក្រសួង ស្ថាប័នពាក់ព័ន្ធ ដោយផ្អែកលើមូលដ្ឋាននៃភាពចាំបាច់ និងស័ក្តិសិទ្ធភាពព្រមទាំងស្របតាមលទ្ធភាពថវិកាជាក់ស្តែង។

- **ក្រសួង ស្ថាប័នត្រូវពិនិត្យលទ្ធភាពនៃការផ្ទេរធនធានថវិកាពីកម្មវិធីមួយទៅកម្មវិធីមួយទៀត ឬ ពីអង្គភាពថវិកាមួយទៅអង្គភាពថវិកាមួយទៀតនៅក្នុងក្រសួង ស្ថាប័នតែមួយឱ្យអស់លទ្ធភាព** ព្រមជាមួយនឹងការថ្លឹងថ្លែងតុល្យភាពនៃការបែងចែកធនធាន និងសិទ្ធិអំណាចទៅតាម និងរវាងអង្គភាពថវិកានីមួយៗ ក្នុងក្របខ័ណ្ឌពិតានកញ្ចប់ថវិកាដែលបានកំណត់ និងត្រូវជៀសវាងការបំប៉ោងចំណាយ ដោយមូលហេតុនៃការអនុវត្តថវិកាសមិទ្ធកម្ម។

- **កសហវ ត្រូវបានអនុញ្ញាតឱ្យកាត់ចេញនូវថវិកាប្រភេទចំណាយមិនប្រចាំផ្ទៃក្នុងក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ ព្រមទាំងរដ្ឋបាលរាជធានី ខេត្ត (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល)។** ទំហំថវិកាដែលនៅសល់ក្នុងក្របខ័ណ្ឌពិតាននេះ អាចជាកម្មវត្ថុនៃការវិភាជសម្រាប់កែលម្អ ឬបង្កើនប្រសិទ្ធភាពនៃកម្មវិធីដែលមានស្រាប់ ឬសម្រាប់កម្មវិធី បម្រើឱ្យគោលនយោបាយថ្មី **នៅក្នុងក្រសួង ស្ថាប័នដដែល ឬទៅក្រសួង ស្ថាប័នមួយផ្សេងទៀត។**

## ៤.២.២. ការគ្រោងចំណាយថវិកាឆ្នាំ ២០២៧ (ត)

- គ. ចំណាយមូលធន/វិនិយោគផ្ទាល់ដោយហិរញ្ញប្បទានថវិកាថ្នាក់ជាតិ (ជំពូក ២១ និង ៦១)

| ក្រសួង | គោលការណ៍អនុវត្ត |
|---|---|
| សាធារណការ, ធនធានទឹក, អភិវឌ្ឍន៍ជនបទ, អប់រំ, សុខាភិបាល, មហាផ្ទៃ, ការងារ, ឧស្សាហកម្ម និង កសហវ (៩ ក្រសួង) | ត្រូវធ្វើសមាហរណកម្មគម្រោងចំណាយវិនិយោគ ជាមួយនឹងគម្រោងចំណាយចរន្តនៅកម្រិតកម្មវិធី និងអនុកម្មវិធី។ ក្រសួងទាំង ៩ ត្រូវរៀបចំបញ្ជីគម្រោងអាទិភាពប្រចាំឆ្នាំឱ្យបានទាន់ពេល ដើម្បីស្នើសុំការសម្រេចពីរាជរដ្ឋាភិបាលជាមុន និងសម្រាប់ជាមូលដ្ឋាននៃការរៀបចំសេចក្ដីព្រាងច្បាប់ថវិកាប្រចាំឆ្នាំ។ |
| កសិកម្ម និងប្រៃសណីយ៍ (២ ក្រសួង) | ត្រូវចាប់ផ្ដើមបន្តសាកល្បងធ្វើសមាហរណកម្មគម្រោងចំណាយវិនិយោគ ជាមួយនឹងគម្រោងចំណាយចរន្តនៅកម្រិតកម្មវិធី និងអនុកម្មវិធី។ ចំពោះការកំណត់អាទិភាព និងជ្រើសរើសគម្រោងដែលក្រសួងនីមួយៗបានស្នើឡើង គឺជាកម្មវត្ថុនៃការពិនិត្យពិភាក្សាតាមយន្តការគណៈកម្មការ ឬក្រុមការងារអន្តរក្រសួង ដោយផ្អែកទៅតាមអាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល និងគោលការណ៍កំណត់អាទិភាពគម្រោងដែលមានចែងនៅក្នុងសារាចរនេះ សម្រាប់ជាមូលដ្ឋានស្នើសុំការពិនិត្យនិងសម្រេចពីរាជរដ្ឋាភិបាល។ |

# ៤.២.២. ការគ្រោងចំណាយថវិកាឆ្នាំ ២០២៧ (ត)

❖ គ. ចំណាយមូលធន/វិនិយោគផ្ទាល់ដោយហិរញ្ញប្បទានថវិកាជាតិ (ជំពូក ២១ និង៦១) (ត)

| ក្រសួង | គោលការណ៍អនុវត្ត |
|---|---|
| ក្រសួង ស្ថាប័នផ្សេងទៀត | ត្រូវសិក្សា និងលើកគម្រោងក្នុងកម្រិតទំហំថវិកាសមស្រប ដើម្បី កសហវ ពិនិត្យ និងរៀបចំអាទិភាពរូបនីយកម្មគម្រោង គោរពស្នើសុំការសម្រេចដ៏ខ្ពង់ខ្ពស់របស់រាជរដ្ឋាភិបាលទៅតាមលទ្ធភាពថវិកាប្រចាំឆ្នាំ។ គម្រោងវិនិយោគដែលអាចស្នើឡើងដើម្បីពិភាក្សា ត្រូវបំពេញតាមគោលការណ៍ និងលក្ខខណ្ឌតម្រូវដែលមានកំណត់នៅក្នុងអនុក្រឹត្យស្តីពីការគ្រប់គ្រងការវិនិយោគសាធារណៈ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ។ |

សម្រាប់អាទិភាពនៃចំណាយវិនិយោគរបស់ក្រសួងទាំង ៨ សូមអានសារាចរនៅទំព័រទី ៣០-៣១។

# ៤.២.២. ការគ្រោងចំណាយថវិកាឆ្នាំ ២០២៧ (ត)

## ឃ. ចំណាយមូលធន/វិនិយោគដោយហិរញ្ញប្បទានសហប្រតិបត្តិការដោយដៃគូអភិវឌ្ឍន៍

ក្រសួង ស្ថាប័នចំនួន ១០ (សូមអានស្លាយទី ២២) ដែលនឹងទទួលបាននូវការវិភាជថវិកាជំពូក ២១ ព្រមទាំងក្រសួង ស្ថាប័នដទៃទៀត ដែលបាននិងកំពុងទទួលបានហិរញ្ញប្បទានសហប្រតិបត្តិការដៃគូអភិវឌ្ឍន៍ ឬគ្រោងនឹងទទួលបានហិរញ្ញប្បទាន ស្របតាមកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល (២០២៧-២០២៩) ត្រូវគ្រោងឱ្យបានត្រឹមត្រូវទៅតាមកិច្ចព្រមព្រៀង ឬអនុស្សារណៈនៃការយោគយល់គ្នា ឬការសន្យាតាមរយៈយន្តការផ្សេងៗ។

# ៤.២.២. ការគ្រោងចំណាយថវិកាឆ្នាំ ២០២៧ (ត)

- <u>**ការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ**</u>

- ដើម្បីធានាឱ្យការរៀបចំថវិកាប្រចាំឆ្នាំកាន់តែមានប្រសិទ្ធភាព **ហើយជាពិសេសធានាឱ្យថវិកាអាចអនុវត្តបានភ្លាមចាប់ពីខែ មករា នៃឆ្នាំសារពើពន្ធ** គ្រប់ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ ព្រមទាំងរដ្ឋបាលរាជធានី ខេត្ត (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល) ត្រូវ៖

  - រៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ សម្រាប់មុខចំណាយដែលត្រូវអនុវត្តនីតិវិធីលទ្ធកម្ម ដោយផ្អែកលើកញ្ចប់ថវិកាដែលគ្រោងស្នើសុំមក កសហវ

  - ផ្ញើផែនការលទ្ធកម្មមកជាមួយនឹងសំណើគម្រោងថវិកាឆ្នាំ ២០២៧ របស់ខ្លួនចំនួនពីរច្បាប់ (មួយច្បាប់បញ្ជូនទៅ <u>អគ្គនាយកដ្ឋានថវិកា</u> និងមួយច្បាប់ទៀតបញ្ជូនទៅ <u>អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ</u> នៃ កសហវ) សម្រាប់ការប្រជុំពិភាក្សាកម្រិតបច្ចេកទេស និងការពិភាក្សាការពារគម្រោងថវិកាកម្រិតថ្នាក់ដឹកនាំក្រសួង។

## ៤.២.២. ការគ្រោងចំណាយថវិកាឆ្នាំ ២០២៧ (ត)

- **ការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ (ត)**

- ផ្អែកលើស្មារតី និងលទ្ធផលនៃការពិភាក្សាថវិកា ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ ព្រមទាំងរដ្ឋបាលរាជធានី ខេត្ត (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល) ត្រូវកែសម្រួលសេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំឱ្យមានសង្គតិភាពជាមួយកញ្ចប់ថវិកា ដែលទទួលបាននៅក្នុងកិច្ចប្រជុំពិភាក្សាថវិកាកម្រិតថ្នាក់ដឹកនាំក្រសួង រួចបញ្ជូនសេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំដែលបានកែសម្រួលរួចនេះ មក កសហវ **យ៉ាងយូរបំផុតត្រឹមសប្តាហ៍ទី ៣ ខែ វិច្ឆិកា** ដើម្បី កសហវ មានពេលវេលាគ្រប់គ្រាន់សម្រាប់ពិនិត្យ និងអនុម័តឱ្យបានមុនថ្ងៃទី ៣១ ខែ ធ្នូ មុនឆ្នាំអនុវត្តថវិកា។

# ៤.២.២. ការគ្រោងចំណាយថវិកាឆ្នាំ ២០២៧ (ត)

❖ **ការរៀបចំផែនការឥណទានរដ្ឋទេយ្យបុរេប្រទាន**

➢ ត្រូវធ្វើឡើងដំណាលគ្នានឹងការរៀបចំគម្រោងផែនការលទ្ធកម្មប្រចាំឆ្នាំ សម្រាប់ពិនិត្យ និងពិភាក្សាក្នុងកិច្ចប្រជុំការពារគម្រោងថវិកាប្រចាំឆ្នាំ។ ក្នុងអំឡុងពេលប្រជុំការពារគម្រោងថវិកា មិនតម្រូវឱ្យពិនិត្យមើលលម្អិតលើតារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទានទេ ប៉ុន្តែក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ ព្រមទាំងរដ្ឋបាលរាជធានី ខេត្ត (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល) ត្រូវធានាថាឥណទានថវិកាដែលត្រូវយកមករៀបចំតារាងឧប-សម្ព័ន្ធរដ្ឋទេយ្យបុរេប្រទាន មិនត្រូវត្រួតគ្នានឹងឥណទានថវិកាដែលត្រូវបានគ្រោងទុកអនុវត្តកិច្ចលទ្ធកម្មសាធារណៈ តាមនីតិវិធីទូទាត់ត្រង់ និងនីតិវិធីចំណាយផ្សេងទៀតទេ។

# ៤.២.២. ការគ្រោងចំណាយថវិកាឆ្នាំ ២០២៧ (ត)

## ❖ ការផ្តល់របាយការណ៍សមិទ្ធកម្ម

- ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ ព្រមទាំងរដ្ឋបាលរាជធានី ខេត្ត (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ត្រូវតែផ្តល់របាយការណ៍សមិទ្ធកម្មនៃការអនុវត្តថវិកាសមិទ្ធកម្មឆ្នាំ ២០២៥ មក **កសហវ (អគ្គនាយកដ្ឋានថវិកា)** ដើម្បីត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្ត ហើយក៏ជាកម្មវត្ថុសម្រាប់ការលើកទឹកចិត្ត ឬការកាត់បន្ថយគម្រោងចំណាយឆ្នាំ ២០២៧។ *នៅពេលពិភាក្សាការពារគម្រោងថវិកាក្រសួង ស្ថាប័ននីមួយៗ ត្រូវតែរៀបចំជាបទបង្ហាញអំពីរបាយការណ៍សមិទ្ធកម្មឆ្នាំ ២០២៥ របាយការណ៍សមិទ្ធកម្មពាក់កណ្តាលឆ្នាំ ២០២៦ និងការគ្រោងលទ្ធផលរំពឹងទុកសម្រាប់ឆ្នាំ ២០២៧។*

## ៤.២.២. ការគ្រោងចំណាយថវិកាឆ្នាំ ២០២៧ (ត)

### ❖ អភិក្រមនៃការពិភាក្សាការពារថវិកា

- **អភិក្រមចំរុះ ដែលបំពេញគ្នាទៅវិញទៅមក និងមានលក្ខណៈទន់ភ្លន់** គឺ៖ តាមរចនាសម្ព័ន្ធកម្មវិធី (កម្មវិធី អនុកម្មវិធី) និងតាមសកម្មភាពការងារ ឬទៅតាមមុខសញ្ញាចំណាយ អាស្រ័យលើកត្តាជាក់ស្តែងនៃរចនាសម្ព័ន្ធថវិកាកម្មវិធីរបស់ក្រសួង ស្ថាប័ននីមួយៗ។ អភិក្រមថ្មីនេះ នឹងជួយកាត់បន្ថយបានជាអតិបរមានូវការពិភាក្សាថវិកាផ្អែកលើធាតុចូល (Input) ដោយតម្រង់ការពិភាក្សាថវិកាដោយផ្អែកលើសកម្មភាព (Activity) និងធាតុចេញ (Output) ជាសំខាន់វិញ។ ទោះជាយ៉ាងនេះក្តី, ការពិភាក្សាដោយផ្អែកលើធាតុចូលក៏នៅតែត្រូវបានគិតគូរលើមុខចំណាយមួយចំនួននៃក្រសួង ស្ថាប័នខ្លះ ដែលត្រូវបានអនុញ្ញាតឱ្យរៀបចំថវិកាសមិទ្ធកម្ម តាមទម្រង់មានលក្ខណៈស្រាល ជាពិសេសក្រសួង ស្ថាប័ន ស្ថិតក្នុងវិស័យរដ្ឋបាលទូទៅ និងវិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់-សាធារណៈ។

## ៤.២.២. ការគ្រោងចំណាយថវិកាឆ្នាំ ២០២៧ (ត)

- ផ្អែកលើមូលដ្ឋាននៃថវិកាឆ្នាំ ២០២៦ ដែលកំពុងអនុវត្ត, ក្នុងការរៀបចំថវិកាឆ្នាំ ២០២៧ ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ អាចពិនិត្យផងដែរទៅដល់បម្រែបម្រួលនៃថវិកាក្នុងអំឡុងពេលអនុវត្ត៖
  - ✓ ចលនាឥណទានដែលបានធ្វើឡើងក្នុងឆ្នាំកំពុងអនុវត្ត ដូចជាការបង្វែរឥណទានថវិកាផ្ទៃក្នុងជំពូក ឬពីជំពូកមួយទៅជំពូកមួយទៀតផ្ទៃក្នុង ឬពីកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាពមួយទៅកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាពមួយទៀត ដែលធ្វើឱ្យឥណទានដើមឆ្នាំ មានការប្រែប្រួល
  - ✓ ការផ្ទេរឥណទានថវិកាបន្ថែមសម្រាប់ផលប្រយោជន៍របស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ។

## ៤.២.២. ការគ្រោងចំណាយថវិកាឆ្នាំ ២០២៧ (ត)

- អនុវត្តតាមប្រកាសលេខ ៣៥៤ សហវ.ប្រក ចុះថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០២២ **ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីកិច្ចបញ្ជិកាគណនេយ្យនៃទ្រព្យសកម្មរយៈពេលវែង**, នៅឆ្នាំ ២០២៦ នេះ, ក្រសួង ស្ថាប័នសរុបចំនួន ២៤ ត្រូវអនុវត្តសាកល្បងនូវគោលការណ៍ខាងលើរួមមាន៖ កសហវ, មហាផ្ទៃ (ផ្នែកសន្តិសុខសាធារណៈ), សុខាភិបាល, កសិកម្ម, ធម្មការ, ការងារ, កិច្ចការនារី, រ៉ែនិងថាមពល, ទេសចរណ៍, អភិវឌ្ឍន៍ជនបទ, អាកាសចរស៊ីវិល, ការពារជាតិ, ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, គ.ជ.ប, ក្រុមប្រឹក្សាធម្មនុញ្ញ, ព័ត៌មាន, ពាណិជ្ជកម្ម, បរិស្ថាន, ប្រៃសណីយ៍, ធនធានទឹក, ឧស្សាហកម្ម, អាជ្ញាធរសវនកម្មជាតិ, អង្គភាពប្រឆាំងអំពើពុករលួយ និងរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន។ សម្រាប់ការគ្រោងថវិកាឆ្នាំ ២០២៧, ក្រសួង ស្ថាប័ន ដែលនៅសេសសល់ ត្រូវបានជ្រើសរើសបន្ថែមសម្រាប់ការអនុវត្តគោលការណ៍ណែនាំតាមគោលការណ៍ខាងលើនេះ ដោយតម្រូវឱ្យផ្លាស់ប្តូរការគ្រោងថវិកាលើមុខចំណាយជាសារវន្តមួយចំនួន (ឧ. ចំណាយទិញរថយន្ត និងចំណាយទិញទោចក្រយានយន្ត) ដែលមានចរិតជាចំណាយមូលធន ដោយប្តូរពីការគ្រោងក្នុងជំពូក ៦០ និងជំពូក ៦១ ទៅក្នុងជំពូក ២០, ជំពូក ២១ ឬជំពូក ២៣ វិញ ស្របតាមវិធីសាស្ត្រដែលមានចែងលម្អិតក្នុងគោលការណ៍ណែនាំនេះ។

# ៤.៣. កាលវិភាគនៃការរៀបចំគម្រោងចំណូល-ចំណាយថវិកាឆ្នាំ ២០២៧

- ឯកសារ ផ.យ.ថ. និងគម្រោងចំណូល-ចំណាយ ជាមូលដ្ឋានចាំបាច់មិនអាចខ្វះបានសម្រាប់**ការពិភាក្សាការពារគម្រោងថវិកាទាំងកម្រិតបច្ចេកទេស និងការពិភាក្សាការពារគម្រោងថវិកាកម្រិតថ្នាក់ដឹកនាំក្រសួង** ដើម្បីធ្វើយុត្តិកម្មកញ្ចប់ថវិការបស់ខ្លួន។

- ក្នុងករណីមិនបានបំពេញព័ត៌មានគ្រប់គ្រាន់ **កសហវ** នឹងជូនព័ត៌មាន ដើម្បីឱ្យក្រសួង ស្ថាប័ន មន្ទីរ-ជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ធ្វើការបំពេញបន្ថែម ហើយប្រសិនបើនៅតែមិនអាចបំពេញបានទេ **កសហវ** មានសិទ្ធិគ្រប់គ្រាន់ក្នុងការយក**មូលដ្ឋាននៃកម្រិតពិតានចំណាយគោល** ដោយប្រើគោលការណ៍កំណត់កញ្ចប់តាមជំពូកខាងលើសម្រាប់កំណត់គម្រោងថវិកាឆ្នាំ ២០២៧។

- តួលេខគម្រោងចំណូល-ចំណាយថវិកា ត្រូវសរសេរជាលេខអន្តរជាតិ ហើយឯកតាទាបបំផុតគិតត្រឹម ០,១ លានរៀល។

## ៥. សេចក្តីសន្និដ្ឋាន

សារាចរនេះ ត្រូវបានរៀបចំឡើងដោយផ្អែកលើគោលបំណងចម្បង ដែលត្រូវបានកំណត់ក្នុងក្របខ័ណ្ឌ **ហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមឆ្នាំ ២០២៧-២០២៩** ពោលគឺ "*ដើម្បីការពារអធិបតេយ្យជាតិ និងបូរណភាពទឹកដី រក្សាលំនឹងជីវភាពប្រជាជននិងជំរុញសម្ទុះកំណើនរយៈពេលមធ្យម ក្នុងបរិការណ៍នៃភាពមិនប្រាកដប្រជាខ្ពស់ដោយធានានូវលទ្ធភាពឆ្លើយតបគ្រប់គ្រាន់ និងចីរភាពហិរញ្ញវត្ថុសាធារណៈ*"។ ទន្ទឹមនេះ, **ក្របខ័ណ្ឌថវិការយៈពេលមធ្យមឆ្នាំ ២០២៧-២០២៩** ក៏បានផ្តល់នូវទស្សនវិស័យអំពីនិន្នាការចំណូល និងចំណាយថវិកាជាតិ ព្រមទាំងកំណត់លម្ហថវិកាដែលសម្រាប់រាជរដ្ឋាភិបាលមានលទ្ធភាពដោះស្រាយ តម្រូវការចំណាយជាយុទ្ធសាស្ត្រ និងជាអាទិភាពសម្រាប់រយៈពេលខ្លី និងមធ្យមក្នុងបរិការណ៍នៃភាពមិនប្រាកដប្រជាខ្ពស់ពីកត្តាខាងក្រៅ។

ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ត្រូវបញ្ជូន ផ.យ.ថ ឆ្នាំ ២០២៧-២០២៩ និងគម្រោងចំណូល-ចំណាយថវិកាឆ្នាំ ២០២៧ របស់ខ្លួន ចំនួន ២ ច្បាប់ មក **កសហវ (អគ្គនាយកដ្ឋានថវិកា)** យ៉ាងយូរបំផុតត្រឹម **ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០២៦**។

សូមអរគុណ!!!

សំណួរ ចម្លើយ